មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិ
សេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និង
សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឱ្យប៉ះពាល់ដល់
កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខ
ជាតិបានឡើយ។ របបសារព័ត៌មាន ត្រូវរៀបចំឡើងកំណត់ដោយច្បាប់។ មាត្រា១០ នៃអនុសញ្ញាអឺរ៉ុប
ស្តីពីសិទ្ធិមនុស្ស បានចែងពីសេរីភាពខាងការបញ្ចេញមតិថា មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពខាង
ការបញ្ចេញមតិ។ សិទ្ធិ
ព័ត៌មាន និងគំនិតនា
មិនមានព្រំដែនកំណត់
ដូចជាទូរទស្សន៍ ឬស
ជាប់ខ្លួន ការអនុវត្តន៍
រឹតត្បិត ឬទោសទណ្ឌ
គោលបំណង ដើម្បី
ដើម្បីទប់ស្កាត់នូវចលា
សិទ្ធិរបស់បុគ្គលដទៃ
សម្ងាត់ ឬដើម្បីរក្សា



# គាំទ្រសង្គមស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា

# ក្រមងឯកសារសម្រាប់ការអនុវត្តន៍ចំពោះសេរីភាព

# នៃការជួបប្រជុំ ការបង្កើតសមាគម និងការបញ្ចេញមតិ

# មាតិកា


១. អំពីយើង
២. សេចក្តីផ្តើម និងបរិបទ
៣. ករណីសិក្សា៖ ព្រឹត្តិការណ៍សង្គមស៊ីវិលអាស៊ាន
៤. កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
៥. សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន
៦. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
៧. ការបរិហារកេរ្តិ៍ជាសាធារណៈ
៨. ការប្តឹងបរិហារបង្អាច់កេរ្តិ៍
៩. ការញុះញង់
១០. ករណីសិក្សា៖ លោក ម៉ម សូណង់ដូ
១១. ការប្រឆាំងនឹងមន្ត្រីសាធារណៈ
១២. ការបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ
១៣. សេចក្តីប្រកាសលេខ ៣៣០ និងលេខ ០៥២
១៤. ព័ត៌មានសម្រាប់ទំនាក់ទំនង

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គឺជាអង្គការឈានមុខ ឯករាជ្យ មិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ដែលធ្វើការលើកកម្ពស់ និងការពារសិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ផ្តល់អំណាចដល់សង្គមស៊ីវិលដើម្បីទទួលបានសិទ្ធិ និងដឹកនាំការផ្លាស់ប្តូរតាមរយៈការស្រាវជ្រាវ និងការវិភាគយ៉ាងលម្អិត យើងបង្កើតនូវគោលនយោបាយថ្មីៗ និងធ្វើការតស៊ូមតិឲ្យមានការអនុវត្ត។

ទស្សនៈវិស័យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គឺកម្ពុជាគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋានមានសិទ្ធិស្មើគ្នា និងត្រូវបានផ្តល់អំណាចឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងការចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍប្រទេសជាតិ។ យើងចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងសង្គមសេរីពហុបក្សដែលភាពចម្រុះត្រូវបានគេស្វែងរក និងអបអរសាទរជាជាងការមិនអើពើ និងការដាក់ទោស។

## សេចក្តីផ្តើម និងបរិបទ

ការវិវឌ្ឍនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាមិនស៊ីសង្វាក់គ្នាជាមួយនឹងកំណើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ឱកាសសម្រាប់សង្គមស៊ីវិលមានកាន់តែតិចទៅៗ ការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន និងការប្រើប្រាស់ប្រព័ន្ធច្បាប់ ដើម្បីជួយគាំទ្រដល់សង្គមស៊ីវិលដែលត្រូវបានចាត់ទុកថា រងការបំពារបំពានកាន់តែច្រើនឡើង។

ដើម្បីលើកឡើងពីបញ្ហាប្រឈមទាំងនេះ ក្រសួងការបរទេសសហរដ្ឋអាមេរិក ការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ បានផ្តល់ជាជំនួយរយៈពេលពីរឆ្នាំ ដល់គម្រោងដែលមានឈ្មោះថា "**គាំពារសង្គមស៊ីវិលនៅកម្ពុជា**"។ ការផ្តល់ជំនួយផ្លូវច្បាប់ដល់ជនរងគ្រោះ ដោយសារការបំពារបំពានសិទ្ធិក៏ដូចជាការជម្រុញឲ្យមានកំណែទម្រង់ដ៏ធ្លីផងនោះ គម្រោងនេះមានគោលដៅបង្កើនការយល់ដឹង និងសមត្ថភាពក្នុងចំណោមអង្គការសង្គមស៊ីវិលនៅកម្ពុជា (អ.ស.ស) លើបញ្ហាសិទ្ធិពាក់ព័ន្ធនឹងសេរីភាពក្នុងការជួបប្រជុំ ការបង្កើតសមាគម និងការបញ្ចេញមតិ។

ការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពនេះ នឹងអាចសម្រេចបានជាបឋមតាមរយៈវគ្គបណ្តុះបណ្តាលរយៈពេលបីថ្ងៃដល់តួអង្គ អ.ស.ស នៅកម្ពុជាដែលបានការពារសេរីភាពក្នុងការជួបប្រជុំ ការបង្កើតសមាគម និងសេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា។

វគ្គបណ្តុះបណ្តាលនេះនឹងត្រូវសិក្សាតាមរយៈឯកសារបោះពុម្ពផ្សាយមួយចំនួន ដែលរួមមានសៀវភៅមគ្គុទ្ទេសក៍សម្រាប់គ្រូបង្គោល សៀវភៅសិក្សាស្តីពីកម្មវិធីបណ្តុះបណ្តាល និងការធ្វើបទបង្ហាញអំពីបញ្ញត្តិច្បាប់ជាក់លាក់មួយចំនួន។ កម្រងឯកសារសម្រាប់អនុវត្តនេះ គឺជាផ្នែកចុងក្រោយនៃឯកសារបោះពុម្ពផ្សាយសម្រាប់វគ្គសិក្សានេះ ព្រមទាំងមានជាឯកសារខ្លីៗដោយសង្ខេបមាត្រាច្បាប់ពាក់ព័ន្ធ និងចំណុចសិក្សាសំខាន់ៗនៅក្នុងវគ្គបណ្តុះបណ្តាលនោះផង។

បណ្តុំឯកសារសម្រាប់អនុវត្ត អាចត្រូវបានប្រើប្រាស់សម្រាប់ជាជំនួយស្មារតីសម្រាប់អ្នកសម្របសម្រួល ដែលរៀបចំវគ្គបណ្តុះបណ្តាល និងផ្តល់ជាប្រយោជន៍ដល់ជនគ្រប់រូបក្នុងប្រទេសកម្ពុជា ដែលអាចទទួលផលប្រយោជន៍ពីការណែនាំខ្លីៗ អំពីសេរីភាពនៃការជួបប្រជុំ ការបង្កើតសមាគម និងការបញ្ចេញមតិ។

## ករណីសិក្សា៖ ព្រឹត្តិការណ៍សង្គមស៊ីវិលអាស៊ាន

ក្នុងដំណើរឆ្ពោះទៅកាន់កិច្ចប្រជុំកំពូលអាស៊ាន នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលមួយចំនួន បានរៀបចំជាសន្និសីទផ្សេងៗ ដើម្បីឲ្យអង្គការសង្គមស៊ីវិលនានាបានពិភាក្សាគ្នាលើបញ្ហានានាដែលប៉ះពាល់ដល់ប្រជាជននៅក្នុងតំបន់អាស៊ាន។ បើទោះជាសកម្មភាពទាំងនេះធ្វើឡើងក្នុងរូបភាពសន្តិភាពទាំងស្រុងក្តី ក៏អាជ្ញាធរបានព្យាយាមរំខានដល់អ្នករៀបចំ ព្រមទាំងបានរាំងដល់ដំណើរការកម្មវិធីទាំងមូល។ ជាក់ស្តែង សន្និសីទសង្គមស៊ីវិលអាស៊ាន/វេទិកាប្រជាជនអាស៊ាន (ACSC/APF) ដែលបានធ្វើឡើងកាលពីថ្ងៃ១៤ ដល់១៦ ខែវិច្ឆិកា ត្រូវបានរំខានយ៉ាងខ្លាំង ក្រោយពីម្ចាស់ទីតាំងបានលុបចោលកិច្ចសន្យាជួលទីតាំងរយៈពេលពីរនាទី ដោយសារតែការដាក់សម្ពាធពីសំណាក់អាជ្ញាធរ។

អ្នករៀបចំសន្និសីទបានជួបប្រជុំគ្នានៅយប់ថ្ងៃទី១៣ ខែវិច្ឆិកា ក្នុងស្នាក់ការតីតស៊ូ និងច្នៃប្រឌិត បានជានាឲ្យមាននូវវេទិកាសាធារណៈមួយនៅភូមិក្តីតាកុយ ខេត្តកណ្តាលដែលមានវេទិកា និងកៅអីតង់ធំ ហើយកៅអីរាប់រយត្រូវបានរៀបចំដោយគ្មានការបារម្ភ។

សិក្ខាសាលាមួយចំនួនបានប្រារព្ធឡើង ដោយបានពិភាក្សាជាចំហរអំពីសារៈសំខាន់នៃសិទ្ធិមនុស្ស និងសេរីភាពទាំងឡាយសម្រាប់ប្រជាជននៅក្នុងតំបន់អាស៊ាន ព្រមទាំងបញ្ហាចម្រុងៗដទៃទៀត ដែលប្រជាជនក្នុងតំបន់អាស៊ានជួបប្រទះមានដូចជា កំណើនសេដ្ឋកិច្ច សន្តិភាព ស្ថិរភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ប្រតិភូមានគ្នាប្រហែលជា ៥០០នាក់ ជាតំណាងឲ្យប្រជាជាតិអាស៊ានទាំងអស់ បានចូលរួមក្នុងព្រឹត្តិការណ៍នោះ។ បរិយាកាសទូទៅក្នុងសន្និសីទប្រព្រឹត្តទៅដោយភាពស្ងៀមស្ងាត់ជាមួយនឹងបទបង្ហាញដែលសង្កត់ធ្ងន់ពីសារៈសំខាន់នៃការចូលរួមក្នុងន័យស្ថាបនាជាមួយនឹងអាជ្ញាធរជាតិ ហើយវារឹតតែពិបាកយល់អំពីមូលហេតុដែលអាជ្ញាធរតែងតែរំខានដល់ព្រឹត្តិការណ៍បែបនេះនៅក្នុងកន្លែងដំបូង។



វេទិកាសាធារណៈនៅខេត្តសៀមរាប ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១

## កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (ក.ស.ស.ស.ន) ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៦៦ ហើយចូលជាធរមានក្នុងឆ្នាំ១៩៧៦។ កតិកាសញ្ញានេះកំណត់ឲ្យប្រទេសជាហត្ថលេខីទាំងអស់លើកកម្ពស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមួយចំនួន ដែលមិនអាចដកហូតបានរួមមាន សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសេរីភាពខាងការបញ្ចេញមតិ។ ក.ស.ស.ស.ន នេះបានបង្កើតឲ្យមានគណៈកម្មា-ធិការសិទ្ធិមនុស្ស ដើម្បីត្រួតពិនិត្យលើការអនុវត្តន៍កតិកាសញ្ញារបស់ប្រទេសជាហត្ថលេខី។ ភាគីទាំងអស់មានកាតព្វកិច្ចបញ្ជូនរបាយការណ៍ស្តីពី ស្ថានភាពនៃការ អនុវត្តសិទ្ធិដែលមានចែងក្នុង ក.ស.ស.ស.ន។

ព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាលើ ក.ស.ស.ស.ន ក្នុងឆ្នាំ១៩៨០ និងបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ ហើយក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាទទួលស្គាល់នូវអនុសញ្ញានានារបស់អង្គការសហប្រជា-ជាតិដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។ ការទទួលស្គាល់នេះត្រូវបានពង្រឹងបន្ថែមដោយសេចក្តីសម្រេចដ៏មានសារៈសំខាន់មួយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានបញ្ជាក់ពីការប្តេជ្ញាអនុវត្តតាមបណ្តាអនុសញ្ញានានាដែលកម្ពុជាបានផ្តល់សច្ចាប័ននៅក្នុងប្រព័ន្ធតុលាការកម្ពុជា។

### មាត្រា ១៩

១. ជនគ្រប់រូបមានសិទ្ធិប្រកាន់យក **មតិយោបល់** ដោយគ្មានការជ្រៀតជ្រែក។

២. ជនគ្រប់រូបមាន **សេរីភាពក្នុងការបញ្ចេញមតិ**។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយពត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយ ដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។

៣. ការប្រើប្រាស់សិទ្ធិដែលមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រានេះ តម្រូវឲ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះអាចមានការរឹតត្បិតមួយចំនួន ដែលត្រូវបានកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី ៖

ក. គោរពសិទ្ធិ និងកិត្តិស័ព្ទរបស់អ្នកដទៃ

ខ. ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។

ទោះបីជាបទបញ្ញត្តិក្នុងកថាខណ្ឌ១ នៃមាត្រា១៩ បានចែងពីសិទ្ធិក្នុងការប្រកាន់មតិដោយគ្មានព្រំដែនកំណត់តែបទបញ្ញត្តិក្នុងកថាខណ្ឌ៣ នៃមាត្រា១៩ បានកំណត់ពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ដែលបានការពារក្នុងកថាខណ្ឌ២នោះនៅក្នុងកាលៈទេសៈជាក់លាក់ណាមួយ។

### មាត្រា ២០

មាត្រា ២០ បានចែងបន្ថែមពីការកំណត់ព្រំដែនលើសេរីភាពក្នុងការបញ្ចេញមតិទាក់ទងនឹងការញុះញង់។ មាត្រានេះបានបញ្ញត្តិ ៖

១. ការឃោសនាណាមួយជាគុណប្រយោជន៍ដល់សង្គ្រាម ត្រូវហាមឃាត់ដោយច្បាប់។

២. ការអំពាវនាវឲ្យមានការស្អប់ខ្ពើមជាតិ ពូជសាសន៍ ឬសាសនាដែលជាការញុះញង់ នាំឲ្យកើតមានការរើសអើង ការប្រទូស្តរាយឬអំពើហិង្សា ត្រូវហាមឃាត់ដោយច្បាប់។

ក្នុងខែកក្កដា ឆ្នាំ២០១១ គណៈកម្មាធិការអង្គការសហប្រជាជាតិបានបោះពុម្ពអត្ថបទវាយតម្លៃទូទៅ ដោយផ្តល់ការកត់សម្គាល់លម្អិតលើការបកស្រាយបញ្ញត្តិមាត្រា១៩ (និងមាត្រា២០បន្តិច)។

### មាត្រា ២១

សិទ្ធិប្រជុំដោយសន្តិវិធីត្រូវតែទទួលស្គាល់។ ការប្រើប្រាស់សិទ្ធិនេះអាចមានការរឹតត្បិត ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់ សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

## សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន

នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ មេដឹកនាំទាំង១០ នៃបណ្តាប្រទេសអាស៊ានបានចុះហត្ថលេខាលើសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន នៅរាជធានីភ្នំពេញ។

សេចក្តីប្រកាសនេះ មិនបានចងកាតព្វកិច្ចផ្លូវច្បាប់ដល់ប្រទេសជាហត្ថលេខីនោះទេ ដែលផ្ទុយពីអនុសញ្ញា។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីប្រកាសបានចែងពីបញ្ហាសីលធម៌យ៉ាងសំខាន់ ហើយអាចជាប្រផ្នូលឆ្ពោះទៅរកអនុសញ្ញា ដែលមានទម្រង់ផ្លូវការជាងនេះនៅប៉ុន្មានឆ្នាំខាងមុខនេះ។

ទោះបីជាដូច្នេះ សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន គឺជាសេចក្តីថ្លែងការណ៍ដ៏សំខាន់មួយ នៃកិច្ចប្រជុំកំពូល។

## ប្រតិកម្មចំពោះសេចក្តីប្រកាស

ដោយមានការយល់ស្របគ្នាទៅតាមបទដ្ឋានសិទ្ធិមនុស្ស នៅថ្នាក់តំបន់អាស៊ានបានយកលំនាំតាមបណ្តាតំបន់ដទៃផ្សេងទៀត ដែលបានបង្កើតឲ្យមានធម្មនុញ្ញក្នុងតំបន់ ដូចជា ធម្មនុញ្ញអាហ្វ្រិកស្តីពី សិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ និងអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ព្រមទាំងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ ទោះបីជាយ៉ាងណាក៏ដោយ កង្វល់ជាច្រើនត្រូវបានលើកឡើងដោយសារតែសេចក្តីប្រកាសអាស៊ានមិនទាន់បំពេញតាមបទដ្ឋានអន្តរជាតិដែលមានស្រាប់ ដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ។ បញ្ហាកង្វល់ជាទូទៅនោះរួមមាន ៖

- កង្វះការប្រឹក្សាយោបល់ដ៏មានសារៈសំខាន់ជាមួយអង្គការសង្គមស៊ីវិលក្នុងដំណាក់កាលនៃការធ្វើសេចក្តីព្រាងនានា
- យោងទៅលើគោលការណ៍ ៧ ស្តីអំពីអង្គហេតុផ្ទុយគ្នា បើទោះបីជាបញ្ហាសិទ្ធិមនុស្សត្រូវបានចាត់ទុកថាជាបញ្ហា “**សកល**” តែការទទួលស្គាល់អំពីបញ្ហាសិទ្ធិមនុស្សនោះ ត្រូវតែពិចារណាជាមុនពីសាវតារ នយោបាយ សេដ្ឋកិច្ច ប្រព័ន្ធច្បាប់ សង្គម វប្បធម៌ ប្រវត្តិសាស្ត្រ និងសាសនា ដែលមានលក្ខណៈខុសគ្នានៅក្នុងតំបន់។ មតិជាច្រើនបានលើកឡើងថា ប្រការនេះអាចធ្វើឲ្យរដ្ឋទាំងអស់មិនខ្វល់ខ្វាយពីទ្រឹស្តីសិទ្ធិមនុស្សជាសកល ហើយធ្វើការបកស្រាយពីសិទ្ធិទាំងនោះ តាមបរិបទក្នុងស្រុករបស់ខ្លួន។
- ជាការពិតដែលគោលការណ៍ ២ មិនបានចែងឲ្យមានច្បាស់ពីបញ្ហាអ្នកស្រលាញ់ភេទដូចគ្នា (LGBT) ថាជាក្រុមមនុស្សមួយប្រភេទដែលអាចអនុវត្តសិទ្ធិរបស់ខ្លួនដោយគ្មានការរើសអើង។
- កង្វះទាំងស្រុងចំពោះយន្តការអនុវត្តការងារដោយឯករាជ្យ ដូចជា តុលាការសិទ្ធិមនុស្ស ឬ គណៈកម្មការសម្រាប់ជម្រុញការអនុវត្តន៍សេចក្តីប្រកាស។
- ជាការពិត ដែលរដ្ឋសមាជិកអាស៊ានអាចចាត់ទុកសេចក្តីប្រកាសនោះមានអំណាចជាងសន្ធិសញ្ញាអន្តរជាតិនានា ហើយបម្រុងនឹងមិនរវល់ពីកាតព្វកិច្ចនានានៅក្នុងសន្ធិសញ្ញាទាំងនោះ។

ដូច្នេះ សង្គមស៊ីវិលជាច្រើនបានទុកសេចក្តីប្រកាសរបស់អាស៊ាននេះ ជាការបោះជំហានថយក្រោយ ហើយវាមិនមែនជាបណ្តុំនៃគោលការណ៍ដែលគេផ្តោតទៅលើនោះទេ។

## រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលកើតឡើងតាមរយៈការបោះឆ្នោតនៅឆ្នាំ១៩៩៣ ដែលត្រូវបានឧបត្ថម្ភដោយអង្គការសហប្រជាជាតិ។ រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលនៅក្នុងប្រទេស។

លិខិតបទដ្ឋានគតិយុត្តទាំងអស់ត្រូវតែអនុលោមតាមរដ្ឋធម្មនុញ្ញ បើពុំនោះទេ នឹងត្រូវចាត់ទុកជាមោឃៈ។ ក្រុមប្រឹក្សាធម្មនុញ្ញមានតួនាទីក្នុងការសម្រេចថា ច្បាប់ទាំងឡាយ (ក្រោមរដ្ឋធម្មនុញ្ញ) ឬសេចក្តីសម្រេចនោះស្របនឹងរដ្ឋធម្មនុញ្ញដែរឬទេ។ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិលើកឡើងពីកង្វល់របស់ខ្លួនដល់ក្រុមប្រឹក្សាធម្មនុញ្ញ។

### សេរីភាពជាមូលដ្ឋាន ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ

មាត្រាជាច្រើនក្នុងរដ្ឋធម្មនុញ្ញមានការពាក់ព័ន្ធនឹងសិទ្ធិសេរីភាពក្នុងការជួបប្រជុំ ការបង្កើតសមាគម និងការបញ្ចេញមតិ ដែលរួមមាន ៖

#### មាត្រា៤១ ៖

- ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។
- របបសាព័ត៌មានត្រូវរៀបចំឡើងដោយច្បាប់។

#### មាត្រា៤២ ៖

- ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

មាត្រាទាំងពីរនេះអាចសបញ្ជាក់ឲ្យឃើញថា សេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំ និងការបង្កើតសមាគម ត្រូវបានការពារយ៉ាងច្បាស់លាស់ក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀត មាត្រា៣១ នៃរដ្ឋធម្មនុញ្ញបានចង្អុលបង្ហាញដោយផ្ទាល់ពីការទទួលស្គាល់ និងការគោរពកតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស។

#### មាត្រា៣១ ៖

- ព្រះរាជាណាចក្រកម្ពុចជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាអន្តរជាតិទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។
- ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ច ដូចៗគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។
- ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់។

## ការបរិហារកេរ្តិ៍ជាសាធារណៈ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ការពារសេរីភាពក្នុងការនិយាយស្តី មតិយោបល់ និងបោះពុម្ពផ្សាយ។ បុគ្គលគ្រប់រូបអាចអនុវត្តសិទ្ធិសេរីភាពនេះ ដោយមិនឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ (មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ)។

បទបរិហារកេរ្តិ៍ត្រូវបានបញ្ញត្តិក្នុងមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

## និយមន័យនៃបទបរិហារកេរ្តិ៍ជាសាធារណៈ

### មាត្រា ៣០៥

គ្រប់ការអះអាងបំផ្លើស ឬការនិយាយទម្លាក់កំហុសដោយអសុទ្ធចិត្តណាមួយ ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទរបស់អ្នកដទៃ ឬនៃស្ថាប័ន គឺជាការបរិហារកេរ្តិ៍។

ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះបទបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមមធ្យោបាយណាមួយដូចតទៅ ៖

១. តាមសំដី ទោះជាប្រភេទណាក៏ដោយ ដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ។

២. តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយ ដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬតាំងឲ្យសាធារណជនមើល។
៣. តាមគ្រប់មធ្យោបាយសារគមនាគមន៍ សោតទស្សន៍សម្រាប់សាធារណជន។

**សេរីភាពខាងមតិយោបល់** ត្រូវបានការពារដោយមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ២០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន។

**សច្ចភាព ៖** ការការពារចំពោះការចោទប្រកាន់ពីបទបរិហារកេរ្តិ៍។

**សុឆន្ទៈ ៖** យុត្តិសាស្ត្ររបស់ប្រទេសបារាំងបានកំណត់ពីលក្ខណៈវិនិច្ឆ័យឲ្យកាន់តែប្រសើរក្នុងការកំណត់ថា តើសុឆន្ទៈពិតជាកើតមានឡើង នៅពេលមានការបរិហារកេរ្តិ៍ដោយគ្មានភស្តុតាងដូចខាងក្រោម ៖

១. គំនិតស្របច្បាប់
២. មិនមានការពាក់ព័ន្ធនឹងគំនុំផ្ទាល់ខ្លួន
៣. ការស៊ើបអង្កេតជាក់លាក់
៤. ការបញ្ចេញមតិដោយប្រុងប្រយ័ត្ន (អាចវាស់វែងបាន)

## ការប្តឹងបរិហារបង្ខាច់កេរ្តិ៍

ការប្តឹងបរិហារបង្ខាច់កេរ្តិ៍ គឺជាបទល្មើសនៃការប្រើប្រាស់បណ្តឹងព្រហ្មទណ្ឌដោយខុសឆ្គងក្នុងការធ្វើឲ្យខូចខាតដល់ជនណាម្នាក់។ វាដូចគ្នានឹងការប្រឌិតរឿងក្តីមួយដើម្បីបង្កើតការចោទប្រកាន់លើបុគ្គលណាម្នាក់ទៀត។ ទោះជាយ៉ាងណាអង្គហេតុមិនគ្រប់គ្រាន់ដែលនាំឲ្យបរាជ័យក្នុងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ពុំដូចគ្នាទៅនឹងការប្តឹងបរិហារបង្ខាច់កេរ្តិ៍នោះទេ។

### និយមន័យនៃការប្តឹងបរិហារបង្ខាច់កេរ្តិ៍

### មាត្រា ៣១១ ក្រមព្រហ្មទណ្ឌ

ការប្តឹងបរិហារបង្ខាច់កេរ្តិ៍ គឺជាអំពើប្តឹងបរិហារអំពីអំពើដែលគេដឹងថាមិនពិត ហើយដែលនាំឲ្យមានបទល្មើសព្រហ្មទណ្ឌ ឬវិន័យកាលបើការប្តឹងបរិហារនេះត្រូវបានផ្ញើទៅដល់ ៖

- អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់ការដូចជា ចៅក្រម មន្ត្រីនគរបាលយុត្តិធម៌ ឬនិយោជក ឬ
- បុគ្គលដែលមានអំណាចប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច។

### មាត្រា ៣១២ ក្រមព្រហ្មទណ្ឌ

ការប្តឹងបរិហារបង្ខាច់កេរ្តិ៍ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែ ដល់មួយឆ្នាំ និង ពិន័យជាប្រាក់ពី ១00.000 (មួយសែន)រៀលដល់ ២.000.000 (ពីរលាន)រៀល។

**បណ្តឹងដែលស្វែងរកដំណោះស្រាយរដ្ឋប្បវេណី ឬពុំមែនព្រហ្មទណ្ឌ ៖** ឧទាហរណ៍ វាមិនមែនជាការប្តឹងបរិហារបង្ខាច់កេរ្តិ៍ ចំពោះការដាក់ពាក្យបណ្តឹងទៅកាន់តុលាការ ពាក់ព័ន្ធនឹងម្ចាស់កម្មសិទ្ធិដីធ្លី។

**សេចក្តីថ្លែងហេតុពុំត្រឹមត្រូវមិនបង្កការប្តឹងបរិហារបង្ខាច់កេរ្តិ៍ ៖** សេចក្តីថ្លែងហេតុពុំត្រឹមត្រូវនៅក្នុងពាក្យបណ្តឹង មិនមានជាតុផ្សំគ្រប់គ្រាន់ក្នុងការបង្កើតឲ្យមានទុច្ចរិតភាព។ ជនជាប់ចោទត្រូវតែដឹងថា អង្គហេតុដែលបានលើកឡើងនោះមិនត្រឹមត្រូវទាំងស្រុង ឬដោយផ្នែក។

**ការធ្វេសប្រហែសមិនបង្កឲ្យមានការប្តឹងបរិហារបង្ខាច់កេរ្តិ៍ ៖** ចាំបាច់ត្រូវតែមានចេតនា។ កំហុសឆ្គងផ្នែកអង្គហេតុដែលកើតមានឡើងពីការធ្វេសប្រហែសមិនមានជាតុផ្សំគ្រប់គ្រាន់ក្នុងការបង្កឲ្យមានទុច្ចរិតភាព។

ភាពខុសគ្នារវាងការបរិហារកេរ្តិ៍ និងការប្តឹងបរិហារបង្ខាច់កេរ្តិ៍ ៖

១. ការប្តឹងបរិហារកេរ្តិ៍ គឺជាការសម្តែងនូវទស្សនៈបង្ខូចទៅកាន់ភាគីទីបី

២. ការប្តឹងបរិហារបង្ខាច់កេរ្តិ៍ គឺជាការបង្ហាញឡើងនូវព័ត៌មានដែលខ្លួនដឹងថាមិនពិតទៅកាន់អាជ្ញាធរមានសមត្ថកិច្ច។

## ការញុះញង់

ច្បាប់ស្ដីពីការញុះញង់ បង្កើតឡើងដើម្បីរារាំងក្នុងការប្រព្រឹត្តអំពើខុសច្បាប់ តែការបញ្ចុះបញ្ចូលជនណាម្នាក់ឲ្យអនុវត្តសិទ្ធិស្របច្បាប់របស់ខ្លួន ពុំមែនជាអំពើខុសច្បាប់ទេ។ ការបញ្ចុះបញ្ចូលប្រជាពលរដ្ឋឲ្យធ្វើបាតុកម្មដោយស្របច្បាប់ពុំមែនជាបទល្មើសនោះឡើយ។ ការញុះញង់ដែលល្អ អាចធ្វើឲ្យមានតុល្យភាពរវាង សេរីភាពនៃការបញ្ចេញមតិ និងសណ្ដាប់ធ្នាប់សង្គម។

## និយមន័យ

ក្រមព្រហ្មទណ្ឌបានលើកឡើងពីការញុះញង់ចំនួនពីរប្រភេទដែលរួមមាន **ការញុះញង់តាមរយៈការផ្ដើមគំនិត** និង **ការញុះញង់ដោយផ្ទាល់**។

## ការញុះញង់តាមរយៈការផ្ដើមគំនិត (មាត្រា២៨)

ត្រូវចាត់ទុកថាជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែល ៖

១. ជម្រុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមតាមរយៈ ការណែនាំ ឬការបញ្ជា

២. បង្កឲ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្ដល់អំណោយ ដោយការសន្យា ឬការគម្រាមកំហែងការញុះញង់ ការល្បួងលោម ឬដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។

អ្នកផ្ដើមគំនិតនឹងអាចត្រូវផ្ដន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬប៉ុនប៉ង។ អ្នកផ្ដើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបានផ្ដន្ទាទោសដូចគ្នានឹងចារីដែរ។

## ការញុះញង់ដោយផ្ទាល់ ឬជាសាធារណៈ (មាត្រា ៤៩៥)

អំពើញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា ៤៩៤ ខាងក្រោមនេះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយខែ ទៅពីរឆ្នាំ និង ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ប្រសិនបើការញុះញង់នោះគ្មានប្រសិទ្ធិភាពទេ។

## លក្ខខណ្ឌអត្ថិភាពនៃការញុះញង់ (មាត្រា៤៩៤)

ដើម្បីអនុវត្តផ្នែកនេះ ការញុះញង់អាចត្រូវផ្ដន្ទាទោសកាលបើអំពើនេះត្រូវបានប្រព្រឹត្ត ៖

១. ដោយសំដីតាមប្រភេទណាក៏ដោយ ដែលត្រូវប្រកាសនៅក្នុងទីកន្លែងសាធារណៈ ឬនៅក្នុងពេលប្រជុំជាសាធារណៈ។

២. ដោយសំណេរ ឬគំនូរតាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬតាំងឲ្យសាធារណជនមើល។

៣. ដោយគ្រប់មធ្យោបាយសារគមនាគមន៍ សោតទស្សន៍សម្រាប់សាធារណជន។

## ការការពារ

**ផ្ដើមប្រព្រឹត្តកំហុសដោយខ្លួនឯង ៖** ឧទាហរណ៍ នៅក្នុងបាតុកម្ម ជនខ្លះអាចប្រព្រឹត្តអំពើចោរកម្មតាមឆន្ទៈរបស់ខ្លួន។

**ពាក្យញុះញង់មិនអាចជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋនោះទេ៖** ការបញ្ចេញពាក្យសម្ដីដោយធ្វេសប្រហែសមិនអាចបញ្ជាក់ពីចេតនាក្នុងការញុះញង់នោះទេ។

**ការអំពាវនាវឲ្យមានសកម្មភាពស្របច្បាប់ ៖** ការអំពាវនាវឲ្យមានសកម្មភាពស្របច្បាប់ ទោះបីជាផ្ទុយនឹងគោលនយោបាយ មិនមែនជាការញុះញង់នោះទេ។

**កង្វះនៃការឲ្យនិយមន័យអំពីសន្តិសុខសង្គម៖** ឧទាហរណ៍ តើការរំខានដល់ចរាចរណ៍ជាការគម្រាមកំហែងដល់សន្តិសុខសង្គមដែរ ឬទេ?

## ករណីសិក្សា លោកម៉ម សូណង់ដូ

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ សាលាដំបូងរាជធានីភ្នំពេញបានចោទប្រកាន់បទល្មើសមួយចំនួនលើ លោកម៉ម សូណង់ដូ ប្រធានសមាគមអ្នកប្រជាធិបតេយ្យ និងជាម្ចាស់ស្ថានីយវិទ្យុសំបុកឃ្មុំ។ បទចោទដែលទាក់ទងនឹងការធ្វើអប្បគមន៍រួមមានការដឹកនាំធ្វើកុប្បកម្មដោយខុសច្បាប់ ការញុះញង់ឲ្យប្រជាពលរដ្ឋកាន់កាប់អាវុធប្រឆាំងនឹងអាជ្ញាធរស្របច្បាប់ ការប្រឆាំងនឹងអ្នករាជការសាធារណៈ ដោយមានស្ថានទម្ងន់ទោស ការជ្រៀតជ្រែកដោយខុសច្បាប់នៅក្នុងការបំពេញមុខងារសាធារណៈ។

នាថ្ងៃទី០១ ខែតុលា សាលាដំបូងរាជធានីភ្នំពេញបានប្រកាសសាលក្រមផ្តន្ទាទោស លោក ម៉ម សូណង់ ដាក់ពន្ធនាគាររយៈពេល២០ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០ លានរៀល (ប្រហែល ២.៥០០ដុល្លា)។ នៅថ្ងៃប្រកាសសាលក្រមនោះ មានប្រជាពលរដ្ឋជាច្រើនរយនាក់បានប្រមូលផ្តុំគ្នានៅក្រៅបរិវេណតុលាការ ហើយត្រូវបានរាំងដោយកងកម្លាំងនគរបាល។

ការផ្តន្ទាទោសលោក ម៉ម សូណង់ដូ បានរងការរិះគន់យ៉ាងខ្លាំងពីសំណាក់អង្គការជាតិ និងអន្តរជាតិព្រមទាំងអាជ្ញាធរអន្តរជាតិ។ ជាឧទាហរណ៍ៈ នៅថ្ងៃទី០១ ខែតុលា ក្រសួងការបរទេសអាមេរិកបានចេញសេចក្តីថ្លែងការណ៍មួយ ដោយបានគូសបញ្ជាក់ពីការគាំទ្រដល់សេរីភាពនៃការបញ្ចេញមតិ រួមមានសិទ្ធិរបស់សមាជិកសារព័ត៌មាន ក្នុងការបញ្ចេញមតិដោយសន្តិភាពចំពោះបញ្ហានយោបាយ ដោយគ្មានការបារម្ភពីការចោទប្រកាន់ ការដាក់ទោស ឬការបំភិតបំភ័យ អនុលោមទៅតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយព្រមទាំង សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

លោក ម៉ម សូណង់ដូ ត្រូវបានដោះលែងឲ្យមានសេរីភាពវិញនៅក្នុងខែមីនា ឆ្នាំ២០១៣ ក្រោយពីសាលាឧទ្ធរណ៍បានកែប្រែការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ ហើយទោសដែលនៅសល់ទាំងអស់ ត្រូវព្យួរ។



លោក ម៉ម សូណង់ដូ នៅសាលាឧទ្ធរណ៍ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១១

## ការប្រឆាំងនឹងមន្ត្រីសាធារណៈ

បទល្មើសនេះច្រើនកើតឡើងនៅពេលដែលប្រជាពលរដ្ឋធ្វើបាតុកម្ម ហើយមន្ត្រីរាជការសាធារណៈមានវត្តមានដើម្បីអនុវត្តច្បាប់។

### តើបាតុកម្មមិនប្រឆាំងនឹងគោលនយោបាយរបស់រដ្ឋាភិ-បាលជាបទប្រឆាំងនឹងអ្នករាជការសាធារណៈដែរឬទេ?

រដ្ឋធម្មនុញធានាដល់សិទ្ធិពលរដ្ឋក្នុងការធ្វើបាតុកម្ម។ បាតុកម្មអហិង្សាពុំមែនជាបទល្មើសទេ ប៉ន្តែជាការអនុវត្តសិទ្ធិរបស់ពលរដ្ឋក្នុងការជួបជុំ និងសេរីភាពបញ្ចេញមតិ។

### អញ្ចឹង! ហេតុអ្វីចាំបាច់មានបទប្រឆាំងនឹងមន្ត្រីរាជការសាធារណៈ?

មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ គ្រាន់តែសំដៅទៅលើអំពើតបតដោយហិង្សាទៅលើអាជ្ញាធរសាធារណៈប៉ណ្ណោះ។ បទបញ្ញត្តិស្ដីពីបទប្រឆាំងនឹងអ្នករាជការសាធា រណៈនោះមានគោលបំណងតែមួយគត់គឺការពារបូរណភាពរាងកាយរបស់អ្នករាជការសាធារណៈ ឲ្យផុតពីការយាយីក្នុងពេលបេសកកម្មរបស់គេដើម្បីឲ្យបេសកកម្មរបស់គេបានសម្រេច។ ជាមួយគ្នានេះ ច្បាប់ក៏គិតគូរដល់សេរីភាពរបស់ពលរដ្ឋក្នុងការបញ្ចេញមតិដែរ។ បទបញ្ញត្តិនេះ ត្រូវតែថ្លឹងឲ្យមានតុល្យភាព រវាងសេរីភាពរបស់ពលរដ្ឋ និងសុវត្ថិភាពរបស់អ្នករាជការសាធារណៈ។

### តើបទល្មើសនេះមានន័យដូចម្ដេចទៅ?

បទល្មើសនេះ មានន័យថា ជាការប្រើហិង្សាទៅលើអ្នករាជការសាធារណៈ ធ្វើឡើងក្នុងការបង្អាក់ ឬបណ្ដេញគាត់មិនឲ្យបំពេញតួនាទី។ ការរំលោភពំពានលើមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ គឺត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ៣ ខែ។

### តើហិង្សានេះមានន័យដូចម្ដេចទៅ?

ជាទូទៅ ហិង្សាជាការប្រើកម្លាំងទៅលើបុគ្គលណាម្នាក់ ដូចជាការវាយ ទាត់ធាក់ ឬ ការគប់ដុំថ្មជាដើម។

### សាធារណៈជន រួមទាំងអ្នករាជការខ្លះផង យល់ថាការសំដែងអាកប្បកិរិយាជំទាស់ទៅនឹងអ្នករាជការសាធា រណៈ គឺជាបទល្មើសប្រឆាំង នឹងអ្នករាជការសាធា រណៈ។ តើពិតជាអញ្ចឹងមែនឬទេ?

ដូចបានបរិយាយខាងលើ បទល្មើសប្រឆាំងអ្នករាជការសាធារណៈ មានធាតុផ្សំមួយគឺ**ហិង្សា**។ រដ្ឋធម្មនុញ្ញ និងកតិកាសញ្ញាអន្តរជាតិដទៃទៀតការពារការសំដែងមតិ ឬការជំទាស់ដោយអហិង្សា។ ច្បាប់មិនមែនតាក់តែងដើម្បីដាក់ទោសអ្នកប្រព្រឹត្តអំពើហិង្សាទេនោះទេ។ ការតវ៉ាដោយសន្តិវិធីអាចធ្វើឡើងតាមគ្រប់ទម្រង់ដូចជា ការដេកនៅកណ្ដាលផ្លូវជាដើម។

### តើអ្នកណាខ្លះដែលចាត់ទុកជាអ្នករាជការសាធារណៈ?

មនុស្សដែលចាត់ទុកថាជាអ្នករាជការសាធារណៈក្នុងគោលបំណងនៃច្បាប់ព្រហ្មទណ្ឌ ត្រូវបានកំណត់នៅក្នុងមាត្រា៣០ នៃក្រមព្រហ្មទណ្ឌ។ អ្នកទាំងនោះអាចជាសមាជិកក្នុងចំណោមអង្គនីតិប្រតិបត្តិ នីតិបញ្ញត្តិ ឬតុលាការ ឬក្នុងសេវាសាធារណៈ។ អ្នកទាំងនោះអាចត្រូវបានជ្រើសរើសតាមការបោះឆ្នោតដូចជា សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់។

### តើពេលណាដែលអ្នករាជការសាធារណៈ ត្រូវបានការពារដោយមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ?

បទល្មើសប្រឆាំងនឹងអ្នករាជការសាធារណៈអាចត្រូវផ្ដន្ទាទោសបានតែនៅពេលណាបុគ្គលជាអ្នករាជការសាធារណៈនោះកំពុងបំពេញមុខងាររបស់ខ្លួនប៉ណ្ណោះ។ ឧទាហរណ៍ ប៉ូលីសចរាចរណ៍កំពុងឈរត្រួតចរាចរណ៍ ប៉ូលីសកំពុងតាមចាប់ជនល្មើសជាដើម។

## ការបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម និងការធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ

### អ្វីទៅជាការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ?

ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ គឺជាការបង្កឲ្យខូចខាតដោយចេតនាដែលជាបទល្មើសព្រហ្មទណ្ឌ យោងតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ។ បទល្មើសនេះត្រូវផ្តន្ទាទោស ពី ៦ ខែ ដល់ ២ ឆ្នាំ និង ពិន័យជាប្រាក់ ពី ១ លានទៅ ៤ លាន រៀល។

### តើបទល្មើសបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ មានការទាក់ទងអ្វីដល់សេរីភាពនៃការបញ្ចេញមតិ សេរីភាពក្នុងការនិយាយ?

បើបទល្មើសនេះសុទ្ធសាធ វាគ្មានអ្វីទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិឬការនិយាយស្តីទេ។ ប៉ុន្តែមាត្រា ៤១០ អាចត្រូវបានប្រើដើម្បីប្រឆាំងសកម្មជនដីធ្លីដើម្បីរារាំងការទាមទារដីរបស់ពួកគេ។ ខណៈពេលមានការតវ៉ាដោយសន្តិវិធីជាវិធីអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិ ភ្លាមនោះការខូចខាតនឹងកើតឡើង ពេលនោះអ្នកតវ៉ាងាយនឹងរងការចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ភាគីម្ខាងទៀត។ ឧទាហរណ៍សមាជិកសហគមន៍ជាច្រើននាក់រងការចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ។ បទចោទដែលលើកឡើងគឺទាក់ទងនឹងការបំផ្លាញផលដំណាំ របង ឬការបង្កឲ្យមានការខូចខាតម៉ាស៊ីនរបស់ភាគីម្ខាងទៀត។

### តើអ្នកតវ៉ាដែលបង្កឲ្យមានការខូចខាតទ្រព្យអ្នកដទៃនឹងត្រូវបានផ្តន្ទាទោសដែរ ឬទេ?

ជាការពិតអ្នកធ្វើខុសត្រូវតែទទួលទណ្ឌកម្ម។ អំពើដែលខុសមិនគួរត្រូវបានការពារនោះទេ ប៉ុន្តែការផ្តន្ទាទោសអាចខុសគ្នាពីករណីមួយទៅករណីមួយទៀត។

### ហេតុអ្វីបានជាការផ្តន្ទាទោសខុសគ្នាអាស្រ័យទៅលើករណីនីមួយៗ?

ដំបូងច្បាប់ចែងថា ការបំផ្លិចបំផ្លាញទ្រព្យអ្នកដទៃអាចត្រូវផ្តន្ទាទោសបាន លុះត្រាណាតែការខូចខាតទ្រព្យសម្បត្តិនោះធំធេងមានន័យថាខូចខាត ធ្ងន់ធ្ងរ។

បន្ទាប់មក ទ្រព្យដែលត្រូវបំផ្លាញនោះត្រូវតែជា "ទ្រព្យសម្បត្តិអ្នកដទៃ"។ មានករណីជាច្រើន ដែលទ្រព្យជាប់ក្នុងជម្លោះនោះមិនអាចកំណត់ថាជាទ្រព្យរបស់អ្នកណាពិតប្រាកដ។ ដូច្នេះ មុននឹងធ្វើការចោទប្រកាន់ថានណាម្នាក់បានបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃផ្សេងទៀត គេត្រូវកំណត់ឲ្យបានច្បាស់ថា តើអ្នកណាជាម្ចាស់ទ្រព្យពិតប្រាកដ។

### ចំពោះរឿងធ្ងន់ស្រាល តើគេអាចកំណត់បានយ៉ាងណាថាវត្ថុមួយរងការខូចខាតធ្ងន់? មានន័យថាខូចខាតប៉ុន្មានទៅហៅថាស្រាល ខូចប៉ុន្មានហៅថាធ្ងន់?

នេះជារឿងមួយពិបាកនឹងកំណត់។ លោក "ក" អាចមើលឃើញថាមានការខូចខាតស្រាល រីឯលោក "ខ" មើលឃើញមានការខូចខាតធ្ងន់ចំពោះរបស់តែមួយដែលបានទទួលការខូចខាត។

មាត្រា ៤១០ ចែងថា "អំពើប្រព្រឹត្តដោយចេតនាដោយបំផ្លិចបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម ឬ ធ្វើឲ្យខូចខាតទ្រព្យរបស់អ្នកដទៃនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ២ ឆ្នាំ និងពិន័យជាប្រាក់ពី ១ លានរៀលទៅ ៤ លានរៀល លើកលែងតែការខូចខាតនោះ មានលក្ខណៈស្រាល"។ ច្បាប់មិនបានបញ្ជាក់ពីទំហំខូចខាតធ្ងន់ធ្ងរ ឬស្រាលទេ ប៉ុន្តែការបកស្រាយច្បាប់អាចធ្វើបានដោយ វិធីច្រើនយ៉ាង។

ជាងនេះទៅទៀតមាត្រា ៤១០ បានកម្រិតពី "ផ្លិចបំផ្លាញ" ទៅ "ធ្វើឲ្យទ្រុឌទ្រោម" និង "ធ្វើឲ្យខូចខាត"។ បើតាមវចនានុក្រមសម្តេចសង្ឃ ជួន ណាត "បំផ្លិចបំផ្លាញ" មានន័យថា ធ្វើឲ្យលង់ហិនហោច ឬធ្វើឲ្យសាបសូន្យ។ "**ទ្រុឌទ្រោម**" មានន័យថា គ្រាំគ្រា ឬធ្វើឲ្យវត្ថុមួយស្រុតមិនអាចឈរបានដោយខ្លួនឯង។ និយាយម្យ៉ាងទៀត គឺលែងអាចប្រើការបានដូចដើម។ "**ខូចខាត**" មានន័យថា សភាពនៃវត្ថុប្រែប្រួលពីសភាពល្អទៅសភាពអន់ជាងមុន។

## សេចក្តីប្រកាសលេខ ៣៣០ និងលេខ ០៥២

យោងតាមសេចក្តីជូនដំណឹងលេខ ៤៧៤ អង្គការ-សមាគម ត្រូវតែសុំការអនុញ្ញាតពីក្រសួងដើម្បីបើកការិយាល័យតាមខេត្ត។ ជាការពិតណាស់អាជ្ញាធរខេត្តខ្លះបានសុំយោបល់មុននឹងខ្លួនអនុញ្ញាតឲ្យបើក ដែលនីតិវិធីនេះមិនស៊ីសង្វាក់គ្នានោះទេ។ ហេតុដូច្នេះ ទើបក្រសួងសម្រេចថា ខ្លួនតែមួយគត់ដែលមានអំណាចសម្រេចអនុញ្ញាតិឲ្យបើកការិយាល័យខេត្តរបស់អង្គការសមាគម។ ទោះបីជាអង្គការ - សមាគមមាន ឬគ្មានការិយាល័យនៅថ្នាក់មូលដ្ឋាន អង្គការ ឬសមាគមទាំងនោះគ្រាន់តែតម្រូវឲ្យ “ជូនដំណឹងប៉ុណ្ណោះ” ដល់អាជ្ញាធរមូលដ្ឋានមុនពេលធ្វើសកម្មភាព។ ពុំមានការតម្រូវឲ្យមានការអនុញ្ញាតនោះទេ។

ទោះជាយ៉ាងណា មាត្រា ១៩ និង ២១ នៃកតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញជាមូលដ្ឋាននៃការតម្រូវឲ្យជូនដំណឹងទៅអាជ្ញាធរខេត្តក្រុងមុននឹងធ្វើសកម្មភាពនេះជាជាងការតម្រូវឲ្យមានការអនុញ្ញាត។

ក្រសួងមហាផ្ទៃ ដោយអាងលើមាត្រាទាំងនេះហើយបានជាទាមទារនៅក្នុងសេចក្តីជូនដំណឹងលេខ ០៥២ ឲ្យសមាគម-អង្គការក្រៅរដ្ឋាភិបាលជូនដំណឹងដល់ អាជ្ញាធរខេត្ត-ក្រុងជាមុនពីការរៀបចំវេទិកាសំដែងមតិ និងឲ្យអាជ្ញាធរខេត្ត-ក្រុងបង្កលក្ខណៈងាយស្រួល និងសហការការពារសន្តិសុខ សុវត្ថិភាពដល់វេទិកាសាធារណៈ។ បើមើលពីភាពវិជ្ជមាន ការទាមទារឲ្យជូនដំណឹងជាមុនអាចជាការងាយស្រួលដល់អាជ្ញាធរមូលដ្ឋានក្នុងការជួយការពារសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងការធ្វើវេទិកាបញ្ចេញមតិដែរ ព្រោះអាចមានជម្លោះកើតចេញពីការជជែកខ្វែងគំនិត ឬការប្រកាន់និន្នាការនយោបាយខុសគ្នា។

នៅក្នុងអធិប្បាយទូទៅលេខ៣៤ របស់គណកម្មាធិការសិទ្ធិមនុស្សដែលជាអង្គឃ្លាំមើលការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្ស និងជាអង្គដែលមានអំណាចធ្វើការបកស្រាយសន្ធិសញ្ញាទាំងនោះផ្តល់ការណែនាំថា ពេលណារដ្ឋដាក់វិធានការកំរិតលើសិទ្ធិ (ដូចជាហាមមិនឲ្យបើកវេទិកាសាធារណៈ ការហាមមិន ឲ្យបង្រៀន)គណៈកម្មាធិការសិទ្ធិមនុស្សលើកឡើងថានៅពេលរដ្ឋធ្វើការរិតត្បិតលើការអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិពុំមែនមានន័យថាសិទ្ធិទាំងនោះទទួលក្តីអន្តរាយឡើយ។

ជាងនេះទៅទៀតបើនិយាយពីឋាននុក្រមនៃច្បាប់វិញ ចំពោះសេចក្តីជូនដំណឹងនេះ ដែលគេហៅថា (សជណ) ស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញ ហើយ សជណ ពុំមានលក្ខណៈចាប់បង្ខំមនុស្សឲ្យអនុវត្តឡើយ។

## ព័ត៌មានសម្រាប់ទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែម ឬ ដំបូន្មាននានា ពាក់ព័ន្ធនឹងបញ្ហាណាមួយនៅក្នុងកម្រងឯកសារនេះ សូមមេត្តាទាក់ទងមក **មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)** ដែលមានអាសយដ្ឋានដូចខាងក្រោម ៖

ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន ប្រអប់ប្រៃសណីយ៍លេខ ១៥០៦ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ (+៨៥៥) ២៣ ៧២៦ ៩០១

ទូរសារ ៖ (+៨៥៥) ២៣ ៧២៦ ៩០២

អ៊ីម៉ែល ៖ info@cchrcambodia.org

គេហទំព័រ ៖ www.cchrcambodia.org

លោកអ្នកអាចស្វែងរកពត៌មាននានា ដែលទាក់ទងនឹងទិដ្ឋភាពសិទ្ធិមនុស្សក្នុងព្រះរាជាណាចក្រកម្ពុជា ដូចជាបញ្ហាប្រឈម និន្នាការសិទ្ធិមនុស្ស និងបញ្ហាផ្សេងៗទៀត នៅក្នុងគេហទំព័រ **www.sithi.org** ។



វេទិកាសាធារណៈនៅខេត្តស្វាយរៀង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១